

# ជាងគំនូរវ័យក្មេង

Cheryl Rao

Tanvi Bhat

letsreadasia.org



នាថ្ងៃឈប់សម្រាកមួយ វីណា និងរ៉ាន់
ណេបានទៅលេងក្នុងសួនច្បារ និង
បានប្រទះឃើញធុងថ្នាំលាបជាច្រើន។



មើលណ៎! មានថ្នាំពណ៌ច្រើនណាស់! មានពណ៌ស! មានពណ៌ក្រហម! មានពណ៌បៃតង! មានពណ៌ខៀវ! មានពណ៌លឿង!



វីណា និងវ៉ាន់ណេឃើញជាងពីរនាក់ កំពុងលាបជញ្ជាំងផ្ទះ។ ជាងម្នាក់ឈរ លើជណ្ដើរ។ ជាងម្នាក់ទៀតអង្គុយ លើទោង។ វីណា និងវ៉ាន់ណេសួរជាង ទាំងពីរនាក់ថា "តើពួកខ្ញុំអាចជួយលាប បានទេ?"



ជាងម្នាក់បានអោយជក់ទៅពួកគេម្នាក់មួយៗ។ គាត់ប្រាប់វីណាថា "ប្អូនលាបទ្វារខាងក្នុង"។ ហើយគាត់ក៏ប្រាប់វ៉ាន់ណេថា "ប្អូនលាបទ្វារខាងក្រៅ"។



វីណា និងវ៉ាន់ណេបានយកធុងថ្នាំលាប ម្នាក់មួយៗ ហើយចាប់ផ្ដើមលាប។ វីណាលាបទ្វារខាងក្នុង។ វ៉ាន់ណេលាបទ្វារខាងក្រៅ។



ថ្នាំពណ៌ស្រក់លើដី ប្រលាក់ពេញ
ជញ្ជាំង និងលើខ្លួនរបស់វីណា និងរ៉ាន់
ណេ។



ពេលវីណា និងវ៉ាន់ណៃលាបរួចរាល់
ពួកគេនាំគ្នាយកទឹកជូតសម្អាតថ្នាំពណ៌
ស្រក់ប្រឡាក់លើដី និងជញ្ជាំង។



ពួកគេក៏មិនភ្លេចសម្អាតថ្នាំពណ៌
ប្រឡាក់លើខោអាវ និងខ្លួនរបស់ពួកគេ
ដែរ។

វីណានិយាយយ៉ាងសប្បាយចិត្តថា ”ខ្ញុំស្រឡាញ់ទ្វារពណ៌ក្រហមរបស់ខ្ញុំខ្លាំងណាស់”។



វ៉ាន់ណេនិយាយថា ”ខ្ញុំស្រឡាញ់ទ្វារ
ពណ៌បៃតងរបស់ខ្ញុំ” ។





បន្ទាប់ពីឃើញទ្វារដែលលាបពណ៌
រួចហើយ ជាងម្នាក់បានលាន់មាត់ថា
"អូ! ទ្វារនេះពីរពណ៌!" អ្នកម៉ាក់ក៏តប
វិញថា "មិនអីទេ! ទុកអោយទ្វារនៅពីរ
ពណ៌បែបហ្នឹងទៅ"។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Little Painters, author: Cheryl Rao . illustrator: by Tanvi Bhat. Published by Pratham Books, https://storyweaver.org.in/stories/218-little-painters © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Solyda Say and Nhean Socheat